# មកុដរបស់បដិមានៃសាសនាព្រាហ្មណ៍-ហិណ្ឌូនៅក្នុងសិល្បៈខ្មែរ

មកុដ ជាគ្រឿងលម្អមួយប្រភេទដែលគេប្រើប្រាស់សម្រាប់លម្អនៅលើសិរសារបស់មនុស្សនិងទេពផ្សេងៗ។ នៅក្នុងវចនានុក្រមខ្មែរច្បាប់ពុទ្ធសាសនបណ្ឌិត្យបោះពុម្ពគ្រាទី៥ លោកឱ្យសេចក្តីពន្យល់ថា មកុដជាគ្រឿងប្រដាប់ធ្វើដោយមាសសុទ្ធ មានរាងក្រឡូមមានកំពូល រំលេចដោយក្បាច់រចនាដ៏វិចិត្រ ដាំត្បូង សម្រាប់ក្សត្រិយ៍ទ្រង់រាជ្យទ្រង់ពាក់ព្រះសិរ, រាប់បញ្ចូលក្នុងរាជកកុធភណ្ឌកុដរាជ្យ។[1] ប៉ុន្តែសម្រាប់បដិមានៃសាសនាព្រាហ្មណ៍-ហិណ្ឌូវិញ មកុដមិនមែនមានត្រឹមតែជាគ្រឿងធ្វើពីលោហៈ មានដាំត្បូងមានតម្លៃល្អវិចិត្រប៉ុណ្ណោះទេ តែមកុដអាចមានច្រើនទម្រង់ទៀត អាស្រ័យទៅតាមលក្ខណៈបដិមាសាស្ត្ររបស់ទេពនីមួយៗនៃសាសនាព្រាហ្មណ៍-ហិណ្ឌូ។

យើងដឹងជាទូទៅហើយថា សង្គមខ្មែរនៅសម័យមុនអង្គរនិងសម័យអង្គរបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីវប្បធម៌ឥណ្ឌា។ ក្នុងនោះខ្មែរក៏បានទទួលយកសាសនាព្រាហ្មណ៍-ហិណ្ឌូពីឥណ្ឌាផងដែរ។ ម្ល៉ោះហើយការសាងរូបបដិមានៃសាសនាព្រាហ្មណ៍-ហិណ្ឌូក្នុងសង្គមខ្មែរនាសម័យនោះ ក៏មានទំនាក់ទំនងទៅនឹងការសាងរូបបដិមានៃសាសនាព្រាហ្មណ៍-ហិណ្ឌូនៅក្នុងសង្គមឥណ្ឌាផងដែរ។ ដូចនេះយើងគួរស្វែងយល់អំពីលក្ខណៈមកុដរបស់បដិមានៃសិល្បៈឥណ្ឌាទៅព្រមគ្នានឹងលក្ខណៈមកុដរបស់បដិមានៅក្នុងសិល្បៈខ្មែរ។

ទម្រង់មកុដដែលពេញនិយមប្រើលម្អលើបដិមាក្នុងសាសនាហិណ្ឌូនៃសិល្បៈឥណ្ឌាមានច្រើនទម្រង់ណាស់ ជាឧទាហរណ៍ ជដាមកុដ (Jaṭāmakuṭa) គិរីដមកុដ (Kirīṭamakuṭa)ករណ្ឌមកុដ(Karandamakuṭa)និងជដាភារ(Jaṭābhāra) ជាដើម។ ចំណែកការប្រើប្រាស់មកុដទាំងនេះសម្រាប់លម្អលើទេពក្នុងសាសនាហិណ្ឌូនៃសិល្បៈឥណ្ឌា ក៏អាស្រ័យទៅតាមលក្ខណៈបដិមាសាស្ត្រនៃទេពនីមួយៗ ដោយគេអាចដឹងបានតាមរយៈព័ត៌មានពីគម្ពីរផ្សេងៗនៅក្នុងសាសនាហិណ្ឌូដែលបានពិពណ៌នាអំពីលក្ខណៈរបស់ទេពទាំងនោះ។ ជាស្តែងនៅក្នុងគម្ពីរសិល្បៈសាស្ត្រ (Śilpaśāstra) មួយចំនួនដែលគេចាត់ទុកជា

[1] ពុទ្ធសាសនបណ្ឌិត្យ, វចនានុក្រមខ្មែរ, ១៩៦៥៖ ៦៣៤។

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

ក្បួនតម្រារបស់ជាងសម្រាប់ការងារសិល្បៈ[២] ដូចជាគម្ពីរអង្សុមទ្ភេទាគម (Anshumadabhedāgama) របស់ឥណ្ឌាខាងត្បូងបានរៀបរាប់ពីលក្ខណៈរបស់ព្រះវិស្ណុថា "...ព្រះវិស្ណុ ទ្រង់គិរីដមកុដនិងក្រវ៉ាត់កដិសូត្រ ទ្រង់ក្រណាត់ពណ៌លឿង មានរូបស្រស់ស្អាត ទ្រង់មានព្រះហត្ថ៤។..." ចំណែកគម្ពីរព្ឫហត្សំហិតា (Bṛhatsaṃhitā) របស់ឥណ្ឌាខាងជើងបានរៀបរាប់លក្ខណៈព្រះវិស្ណុថា "..ព្រះវិស្ណុមានដៃ៨ ដៃ៤ ឬដៃ២ក៏បាន ... ទ្រង់ក្រណាត់ពណ៌លឿង មានព្រះភក្ត្របរិសុទ្ធិ ទ្រង់ទុំហូនិងគិរីដមកុដ..."។[៣]

ខាងក្រោយនេះខ្ញុំនឹងលើកយកតែប្រភេទមកុដរបស់បដិមាព្រាហ្មណ៍-ហិណ្ឌូដែលប្រទះឃើញជាញឹកញាប់នៅក្នុងសិល្បៈខ្មែរមកបង្ហាញប៉ុណ្ណោះគឺ ជដាមកុដ និងគិរីដមកុដ ដោយប្រៀបធៀបលក្ខណៈនៃមកុដទាំងនេះជាមួយនឹងលក្ខណៈមកុដរបស់បដិមានៃសាសនាព្រាហ្មណ៍-ហិណ្ឌូក្នុងសិល្បៈឥណ្ឌា។

**ជដាមកុដ៖** ជាទម្រង់មកុដមួយប្រភេទដែលកើតឡើងពីការបួងសក់ឡើងលើឱ្យកើតជាផ្នួង រួចទម្លាក់សក់ដែលនៅសល់ឱ្យសំយុងចុះក្រោម។ ពាក្យថា "ជដា" មានន័យថា "ផ្នួងសក់" ហេតុនេះជដាមកុដបានក្លាយជាទម្រង់មកុដដែលគេកំណត់សម្រាប់ទេពដែលមានឋានៈជាអ្នកបួស ដូចជា ព្រះព្រហ្មណ៍ ព្រះសិវៈ ព្រះឧមា រួមទាំងព្រះពោធិសត្វមួយចំនួនធំនៃពុទ្ធសាសនាមហាយានផងដែរ។ នៅក្នុងសិល្បៈឥណ្ឌាលេចឡើងការធ្វើជដាមកុដទាំងតាំងពីសិល្បៈគន្ធារៈ(ស.វទី១-៣)មកម្ល៉េះ[៤]ហើយបន្តនិយមមកសម័យក្រោយៗទៀត (**រូបលេខ១**)។ សម្រាប់សិល្បៈខ្មែរវិញ យើងឃើញទេពដែលមានឋានៈជាអ្នកបួសក៏មានលម្អដោយជដាមកុដ ដែលមានលក្ខណៈជាការបួងសក់ឡើងដូចបដិមាហិណ្ឌូនៃសិល្បៈឥណ្ឌាដែរ ដូចជាបដិមាព្រះសិវៈ និងព្រះព្រហ្មជា ព្រះឧមាដើម។ លក្ខណៈជដាមកុដនៅសម័យដំបូងមានលក្ខណៈជាការបួងសក់ឡើងទៅលើរួចចងដោយសរសៃសក់ពី១ថ្នាក់ទៅ៣ថ្នាក់ បន្ទាប់មកទម្លាក់សក់ដែលនៅសល់ឱ្យសំយុងចុះពីចំហៀងក្បាលឬពី

---

[២] Chedha Tingsanchali 2016: 12.

[៣] ដដែល: ៦០-៦៤។

[៤] Chedha Tingsanchali 2019: 25.

*ខាងមុខ(**រូបលេខ២-៣**)។ ក្រោយមកនៅសម័យអង្គរ ផ្នួងសក់ចាប់ផ្ដើមមានលក្ខណៈខុសធម្មជាតិ ពោលគឺផ្នួងសក់មានរាងជាស៊ីឡាំង និងមានចង្វាយសក់ល្អិតៗរាងកោងទម្លាក់សំយុងចុះក្រោយរៀងគ្នាជាជួរ ឬធ្វើជាសរសៃត្រួតលើគ្នាជាជួរផ្ដេកក៏មាន។ ពេលខ្លះមានការលម្អបន្ថែមនូវក្បាំងពីខាងមុខផ្នួងសក់បដិមាដែរ ដែលនេះជាលក្ខណៈពិសេសមួយនៃសិល្បៈខ្មែរ (**រូបលេខ២៤-៥**)។*

***គិរីដមកុដ៖*** *ជាមកុដមានរាងខ្ពស់ លម្អដោយត្បូងនិងគ្រឿងលម្អផ្សេងទៀត ពេលខ្លះនៅខាងលើមានប្រដាប់ដោយដុំមូល។[៥] ពាក្យថា "គិរីដ" មានន័យថា "មកុដ" ហេតុនេះហើយទើបក្នុងបដិមាសាស្ត្រកំណត់ឱ្យមកុដប្រភេទនេះជាមកុដរបស់ទេពក្នុងសាសនាហិណ្ឌូដែលមានឋានៈជាក្សត្រ ដូចជា ព្រះឥន្ទ្រជាស្ដេចនៃពួកទេវតា ព្រះវិស្ណុមាននាទីជាអ្នករក្សាចលោកប្រៀបបាននឹងក្សត្រដែលមើលថែរក្សាអាណាចក្រ ព្រះយមជាស្ដេចនៃយមលោក ជាដើម។ ជដាមកុដអាចមានទម្រង់ជាក្រណាត់ជួតក្បាល ឬមានទម្រង់ជាមួករាងស៊ីឡាំង ក៏បាន។[៦] សម្រាប់បដិមាហិណ្ឌូក្នុងសិល្បៈខ្មែរនៅសម័យដំបូងៗ យើងសង្កេតឃើញថា គិរីដមកុដរបស់បដិមាមានលក្ខណៈជាមួករាងស៊ីឡាំងរាបស្មើមិនមានការតុបតែងលម្អអ្វីទាំងអស់(**រូបលេខ២៦**) លក្ខណៈនេះដូចគ្នាយ៉ាងខ្លាំងទៅនឹងរូបរាងគិរីដមកុដរបស់បដិមានៃសិល្បៈឥណ្ឌា ជាពិសេសបដិមានៅដើមសម័យសិល្បៈបល្លាវៈរបស់ឥណ្ឌាខាងត្បូង (**រូបលេខ២៧**)។ ក្រោយមកនៅសម័យអង្គរគិរីដមកុដនៃសិល្បៈខ្មែរចាប់ផ្ដើមមានការវិវត្តចេញ ឆ្ងាយពីលក្ខណៈគិរីដមកុដរបស់ឥណ្ឌា ពោលគឺចាប់ផ្ដើមមានរាង៨ជ្រុងនិងមានមន្ថែមក្បាំងនៅខាងមុខផងដែរ(**រូបលេខ២៨**)។ ក្រោមមកទៀត ផ្នែក៨ជ្រុងរបស់គិរីដមកុដនឹងមានការវិវត្តទៅជាស្រួចបន្តិចម្ដងៗ ហើយនៅទីបំផុតនឹងមានលក្ខណៈស្រួចខ្លាំងនៅក្នុងរចនាបទអង្គរវត្តស.វទី១២(**រូបលេខ២៩**)។*

[៥] James G. Lochtefeld 2002: 367.

[៦] Chedha Tingsanchali 2019: 63.

*អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់*

ការលម្អមកុដនៅលើបដិមាហិណ្ឌូក្នុងសិល្បៈខ្មែរ ហាក់បានគោរពខ្ជាប់ខ្ជួនទៅតាមលក្ខណៈបដិមាសាស្ត្ររបស់បដិមា។ ជាឧទាហរណ៍ដ៏ល្អមួយ យើងអាចសង្កេតទៅលើទម្រង់មកុដរបស់ព្រះហរិហរដែលជាអាទិទេពកើតចេញពីការផ្សំគ្នារវាងព្រះសិវនិងព្រះវិស្ណុ ម្ល៉ោះហើយមកុដរបស់ទ្រង់ក៏មានលក្ខណៈផ្សំគ្នាផងដែរ។ ដោយផ្នែកខាងស្តាំជារូបព្រះសិវទ្រង់គ្រងជដាមកុដមានលក្ខណៈជាសក់បួងឡើងលើជាផ្នួងសក់ ចំណែកផ្នែកខាងឆ្វេងវិញជារូបព្រះវិស្ណុទ្រង់គ្រងគិរីដមកុដមានលក្ខណៈជាមួកមានពងស៊ីឡាំងឬ៨ជ្រុង (**រូបលេខ១០-១១**)។

សរុបមកមកុដជាធាតុមួយដែលអាចជួយឱ្យយើងអាចកំណត់អត្តសញ្ញាណរបស់បដិមាបាននៅត្រឹមកម្រិតបឋមតែប៉ុណ្ណោះ។ ការកំណត់អត្តសញ្ញាណរបស់មដិមាមួយឱ្យមានភាពច្បាស់លាស់គួរគប្បីត្រូវពិនិត្យលើធាតុផ្សំផ្សេងៗជាច្រើនទៀតដូចជាកេតនភណ្ឌដែលបដិមាកាន់ គ្រឿងស្លៀកពាក់ ជាដើម។ តែយ៉ាងណាក៏ដោយ តាមរយៈការបង្ហាញខាងពីលើនេះធ្វើឱ្យយើងយល់បានថា សង្គមខ្មែរសម័យបុរាណមិនត្រឹមតែទទួលយកឥទ្ធពលសាសនាព្រាហ្មណ៍-ហិណ្ឌូពីឥណ្ឌាប៉ុណ្ណោះទេ តែថែមទាំងបានទទួលយកមកជាមួយនូវលក្ខណៈបដិមាសាស្ត្របែបឥណ្ឌាផងដែរ។ រឿងដែលសំខាន់ជាងនេះទៅទៀត ជាងខ្មែរសម័យបុរាណពីមួយជំនាន់ទៅមួយជំនាន់ចេះអភិវឌ្ឍលក្ខណៈបដិមាសាស្ត្ររបស់ខ្លួនឱ្យលក្ខណៈពិសេសស្របតាមរសនិយមរបស់ខ្លួន ដែលនេះជាកត្តាមួយធ្វើឱ្យបដិមាហិណ្ឌូនៃសិល្បៈខ្មែរមានលក្ខណៈលេចធ្លោក្នុងចំណោមសិល្បៈផ្សេងៗក្នុងតំបន់៕

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

# បញ្ជីឯកសារយោង


ពុទ្ធសាសនាបណ្ឌិត្យ.

១៩៦៥. *វចនានុក្រមខ្មែរ, ភ្នំពេញ។*

James G. Lochtefeld

2002. The Illustrated Encyclopedia of Hinduism, The Rosen Publishing Group, Inc, New York.

Tingsanchali, Chedha.

2016. *Hindu and Buddhist Sculpture in India: The Coincidence with Sanskrit Śilpaśāstra Scriptures,* Ruen Kaew Printing, Bangkok.

2019. *The Role Indian Influence to the Dress of Sculpture in Southeast Asian Art*. Matichon, Bangkok.


# បញ្ជីរូបភាព



រូបភាពទី១៖ មុខលិង្គពីភូមិ Khoh សិល្បៈគុប្តៈ ស.វទី៥ សារមន្ទីរ Allahabad ប្រទេសឥណ្ឌា

(រូបថត៖ https://www.pinterest.com/pin/441212094725732941/)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបភាពទី២៖ មុខសិង្គ ទួលអ្នកតាស្វាយដំបរ កណ្ដាល (រូបថត៖ EFEO_CAM12635)



រូបភាពទី៣៖ ព្រះព្រហ្ម សម្បូរព្រៃគុក កំពង់ធំ ស.វ.ទី៧ (រូបថត៖ EFEO_CAM 03176_2)



រូបភាពទី៤៖ ព្រះព្រហ្ម បាសែត បាត់ដំបង ស.វ.ទី១០ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបភាពទី៥៖ ព្រះសិវៈ បាគង សៀមរាប ស.វ.ទី៩ សារមន្ទីរជាតិភ្នំពេញ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបភាពទី៦៖ ព្រះវិស្ណុ អង្គបុរី តាកែវ ស.វ.ទី៧
(រូបថត៖ ឡេង ស៊ីវ៉ង)



រូបភាពទី៧៖ ព្រះវិស្ណុផ្ទំ Mahabalipuram
សិល្បៈបល្លវៈ ស.វ.ទី៧ (រូបថត៖ ឡេង ស៊ីវ៉ង)



រូបភាពទី៨៖ ព្រះវិស្ណុ បាគង សៀមរាប ចុងស.វ.ទី៩
សារមន្ទីរជាតិភ្នំពេញ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបភាពទី៩៖ ព្រះវិស្ណុ សៀមរាប ស.វ.ទី១២
សារមន្ទីរជាតិភ្នំពេញ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបភាពទី១០៖ ព្រះហរិហរ ភ្នំដា ស.វ.ទី៦ ថតនៅសារមន្ទីរ Guimet (រូបថត៖ Sakchai Saisingha)



រូបភាពទី១១៖ ព្រះហរិហរ ស.វ.ទី១០ ថតនៅសារមន្ទីរAsian Civilizations (រូបថត៖ ឡេង ស៊ីវ៉ង់)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់